សំណើ

# 3 សិទ្ធិតាមរដ្ឋធម្មនុញ្ញចំពោះអាពាហ៍ពិពាហ៍។ វិសោធនកម្មរដ្ឋធម្មនុញ្ញច្បាប់។

**ចំណងជើងផ្លូវការ និងសេចក្តីសង្ខេប** រៀបចំដោយអគ្គព្រះរាជអាជ្ញា

3

**អត្ថបទស្តីពីវិធានការនេះអាចរកបាននៅទំព័រទី 75 និងនៅវិបសាយថ៍រដ្ឋលេខាធិការតាមរយ *voterguide.sos.ca.gov*។**

- ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ California ដើម្បីទទួលស្គាល់សិទ្ធិជាមូលដ្ឋានក្នុងការរៀបការដោយមិនគិតពីភេទ ឬពូជសាសន៍។
- លុបភាសានៅក្នុងរដ្ឋធម្មនុញ្ញ California ដែលចែងថាអាពាហ៍ពិពាហ៍គឺអាចធ្វើឡើងរវាងបុរសនិងស្ត្រីតែប៉ុណ្ណោះ។

**សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់អ្នកវិភាគនីតិបញ្ញត្តិ អំពីផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖**

- មិនមានការផ្លាស់ប្តូរចំណូល ឬការចំណាយសម្រាប់រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋានទេ។

ការបោះឆ្នោតចុងក្រោយដោយអង្គនីតិបញ្ញត្តិនៅលើ ACA 5 (សំណើ 3)
(ជំពូកទី 125 លក្ខន្តិកៈឆ្នាំ 2023)

| | | |
|---|---|---|
| ព្រឹទ្ធសភា៖ | បោះឆ្នោតគាំទ្រ 31 | បោះឆ្នោតមិនគាំទ្រ 0 |
| សភា៖ | បោះឆ្នោតគាំទ្រ 67 | បោះឆ្នោតមិនគាំទ្រ 0 |

**ការវិភាគដោយអ្នកវិភាគច្បាប់**

## ផ្ទៃខាងក្រោយ

តុលាការសហព័ន្ធបាននិយាយថា គូស្នេហ៍ភេទដូចគ្នាអាចរៀបអាពាហ៍ពិពាហ៍បាន ក៏ប៉ុន្តែភាសាហួសសម័យនៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋ California នៅតែនិយាយថា ការរៀបអាពាហ៍ពិពាហ៍ អាចមានតែរវាងបុរសនិងស្ត្រីប៉ុណ្ណោះ។

## សំណើ

សំណើ 3 ធ្វើបច្ចុប្បន្នភាពរដ្ឋធម្មនុញ្ញដើម្បីឱ្យត្រូវនឹងអ្វីដែលតុលាការសហព័ន្ធបាននិយាយអំពីអ្នកដែលអាចរៀបអាពាហ៍ពិពាហ៍បាន។

## ផលប៉ះពាល់សារពើពន្ធ

សំណើ 3 នឹងមិនផ្លាស់ប្តូរអ្នកដែលត្រូវបានអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាននៅក្នុងរដ្ឋ California ទេ។ មានន័យថា នឹងមិនមានការផ្លាស់ប្តូរចំណូល ឬការចំណាយចំពោះរដ្ឋាភិបាលរដ្ឋ និងក្នុងតំបន់ទេ។

**សូមចូលទៅកាន់ *sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2024-ballot-measure-contribution-totals* សម្រាប់បញ្ជី គណៈកម្មាធិការ បង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬប្រឆាំងវិធានការនេះ។**

**សូមចូលទៅកាន់ *fppc.ca.gov/transparency/top-contributors.html* ដើម្បីចូលមើលអ្នកជួយវិភាគទានកំពូលទាំង 10 របស់គណៈកម្មាធិការ។**

សម្រាប់អត្ថបទពេញស្តីពីសំណើ 3 សូមមើលទំព័រទី 75។